# មេរៀនទី ៨៨៖ យ៉ូស្វេក្លាយជាអ្នកដឹកនាំ ជនជាតិអ៊ីស្រាអែល

## យ៉ូស្វេ១៖១-១១

**មេរៀន** *( យូធូបលីង )*៖ https://youtu.be/dgokRof4mCI

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/N-rSk0GOGBs

**គោលបំណង៖** ព្រះអង្គលើកយើងឡើង ហើយទ្រង់តែងតែគង់នៅជាមួយយើង

**ខគម្ពីរចងចាំ៖ យ៉ូស្វេ ១៖៩** *“......ចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែងណា ដែលឯងទៅផង”។*

**ចំរៀង** *(យូធូបលីង)*៖

១. បើទ្រង់គង់ជាមួយ https://youtu.be/2CzIW4_ueg0

២. ខ្ញុំចូលតាមទ្វារព្រះអង្គ https://youtu.be/WvXL4DtBMdc

៣. ពេលខ្យល់ព្យុះបក់ខ្លាំង https://youtu.be/lI5A7jKQb2o

## ១. អធិស្ឋាន

## ២. ចំរៀង *( រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស )*

## ៣. ល្បែងកំសាន្ត « **ការផ្ដល់ការលើកទឹកចិត្ត និងការសសើរ** »




១.ចែកកុមារជាពីរក្រុមដោយក្រុមនីមួយៗ

២.ត្រូវប្ដូរវេនគ្នាម្ដងម្នាក់និយាយអ្វីដែលជាពាក្យលើកទឹកចិត្តទៅកាន់មិត្តភក្ដិរបស់គេដូចជា “អ្នកពិតជាអស្ចារ្យមែន!” “ត្រូវរឹងមាំឡើង!” ឬ “អ្នកអាចធ្វើវាបាន!”

៣. គ្រូសរសេរ ពាក្យលើកទឹកចិត្តដែលសិស្សបាននិយាយនោះដាក់នៅលើក្ដារខៀន គ្នាជាលំដាប់កាំជណ្ដើរ ម្ខាងសំរាប់មួយក្រុមៗ ។

៥. នៅពេលដែលក្រុមណាមួយរកពាក្យលើកទឹកចិត្តនិយាយទៀតមិនបាន ក្រុមទាំងសងខាងនឹងត្រូវបញ្ឈប់ ហើយគ្រូនឹងគូសភ្ជាប់ជណ្ដើរទាំងសងខាងនោះជាមួយគ្នា ហើយគូររូបមនុស្សម្នាក់ នៅខាងលើជណ្ដើរដែលគូភ្ជាប់នោះ។ សូមរំឭកកុមារឱ្យចេះលើកទឹកចិត្តគ្នាទៅវិញទៅមក ព្រោះព្រះតែងតែលើកទឹកចិត្តយើង!

## ៤. ការណែនាំមេរៀន

ព្រះអង្គស្រលាញ់អ្នក ហើយទ្រង់ចង់លើកទឹកចិត្តអ្នកនៅថ្ងៃនេះ។ តើអ្នកដឹងទេថាព្រះមានផែនការដ៏អស្ចារ្យសំរាប់ជីវិតរបស់អ្នក? តើអ្នកដឹងទេថាព្រះតែងតែគិតពីអ្នកគ្រប់ពេលវេលា? ហើយតើអ្នកដឹងទេថាព្រះអង្គតែងតែគង់ជាមួយអ្នកគ្រប់ទីកន្លែងដែលអ្នកទៅ? ព្រះបានធ្វើការទាំងអស់នោះ! នៅពេលយើងលើកទឹកចិត្តនរណាម្នាក់ គឺយើងបានផ្ដល់ឱ្យពួកគេនូវ ភាពក្លាហាន ក្ដីសង្ឃឹម និងទំនុកចិត្ត។ ថ្ងៃនេះយើងនឹងរៀន អំពីបុរសម្នាក់ឈ្មោះ យ៉ូស្វេដែលគាត់ពិតជាត្រូវការការលើកទឹកចិត្តពីព្រះ។ សូមស្វែងយល់ពីរបៀបដែល ព្រះលើកទឹកចិត្ត យ៉ូស្វេ!

## ៥.រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីលោកម៉ូសេបានស្លាប់ទៅ ព្រះបានប្រាប់មនុស្សជំនិតរបស់គាត់ដែលជាបុរសវ័យក្មេងម្នាក់ឈ្មោះ យ៉ូស្វេ ថាគាត់នឹងក្លាយជាអ្នកដឹកនាំថ្មីបន្តពីម៉ូសេ។ សូមស្រមៃអំពីការជំនួសតំណែងនរណាម្នាក់ដូចជា

តំណែងរបស់ម៉ូសេ - លោកម៉ូសេគឺជាអ្នកដែលបាន ដឹកនាំជនជាតិអ៊ីស្រាអែលចេញពី អេហ្ស៊ីបឆ្លងកាត់សមុទ្រក្រហម និងឆ្លងកាត់វាលរហោស្ថាន! សាកស្រមៃមើលថា បើភ្លាមៗអ្នក បានក្លាយជាគ្រូគង្វាលនៃក្រុមជំនុំដ៏ធំមួយតើអ្នកនឹងមានអារម្មណ៍ដូចម្តេច?! តើអ្នកនឹងមានការភ័យខ្លាច ហើយព្រួយបារម្ភមែនដែរឬទេ? តើអ្នកគិតថាយ៉ូស្វេមានអារម្មណ៍យ៉ាងណា? យ៉ូស្វេប្រហែលជាមានអារម្មណ៍ភ័យខ្លាច ពីព្រោះការងារនេះពិតជាធំណាស់។ គាត់ប្រហែលជាឆ្ងល់ថាតើគាត់អាចដឹកនាំ ជនជាតិអ៊ីស្រាអែលបានល្អដូចជាម៉ូសេដោយរបៀបណា?

ទោះបីជាយ៉ូស្វេភ័យខ្លាចក្នុងការជំនួសកន្លែង របស់ម៉ូសេក៏ដោយ ក៏ព្រះចង់ឱ្យគាត់មានភាពរឹងមាំ និងពោរពេញដោយភាពក្លាហាន។ (សូមថតចំលងព្រះគម្ពីរយ៉ូស្វេ ១៖៧-៩ ហើយអានឲ្យកុមារស្តាប់ សូមមើលនៅទំព័រខាងក្រោម) ព្រះមានបន្ទូលទៅកាន់ លោកយ៉ូស្វេ (***យ៉ូស្វេ ១៖៧-៩***) **“ឲ្យឯង គ្រាន់តែមានកំឡាំងនិងចិត្តក្លាហាន ប៉ុណ្ណោះដើម្បីនឹងកាន់ ហើយប្រព្រឹត្តតាមក្រឹត្យវិន័យគ្រប់ជំពូក ដែលម៉ូសេជាអ្នកបំរើអញបាន បង្គាប់មកកុំឲ្យងាកបែរចេញទៅខាងស្តាំឬខាងឆ្វេងឡើយ ប្រយោជន៍ឲ្យ ឯងបានកើតការនៅកន្លែងណា ដែលឯងទៅនោះកុំឲ្យគម្ពីរក្រឹត្យវិន័យនេះភ្លេចបាត់ ពីមាត់ឯងឡើយ គឺ ត្រូវឲ្យនឹកជញ្ជឹងទាំងយប់ទាំងថ្ងៃវិញ ដើម្បីឲ្យបានកាន់ ហើយប្រព្រឹត្តតាម អស់ទាំងសេចក្តី ដែលកត់ ទុកក្នុងគម្ពីរនេះឯង ដ្បិតគឺយ៉ាងនោះដែលឯងនឹងបានកើតការ នៅគ្រប់ទាំងផ្លូវឯង ហើយនឹងបាន ចំរើនឡើងផង តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឲ្យមាន កំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាច ឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែងណា ដែលឯងទៅផង”** ជាមួយនឹងការលើកទឹកចិត្តពីព្រះ យ៉ូស្វេបានក្លាយជាមេដឹកនាំដ៏ល្អរបស់ជនជាតិអ៊ីស្រាអែល!

ព្រះមាន ផែនការសំរាប់យើងម្នាក់ៗ ដូចជាទ្រង់មាន ផែនការសំរាប់យ៉ូស្វេដូច្នេះដែរ។ ហើយអ្នកមិនចាំបាច់ចាំរហូតដល់យើងធំនោះទេ។ អ្វីដែលព្រះអង្គចង់ឲ្យយើងធ្វើក្នុងពេលឥឡូវនេះ គឺឲ្យយើងស្រលាញ់អ្នកដ៏ទៃ ទៅសាលារៀនខិតខំរៀនសូត្រ និងស្តាប់បង្គាប់ឪពុកម្តាយ ។ ពេលខ្លះវាពិបាកខ្លាំងណាស់ក្នុងការស្រឡាញ់ អ្នកដទៃ ឬស្តាប់បង្គាប់ឪពុកម្តាយ ឬក៏ធ្វើកិច្ចការផ្ទះរបស់យើងជារៀងរាល់ថ្ងៃ។ ព្រះចង់ជួយយើង និង លើកទឹកចិត្តយើងនៅពេលដែលរឿងទាំងនោះមើលទៅហាក់ដូចជាពិបាកធ្វើពេកសម្រាប់យើង។ ព្រះជាម្ចាស់ទ្រង់នៅខាងយើងដើម្បីជួយណែនាំ និងលើកទឹកចិត្តយើងនៅថ្ងៃនេះតាមរបៀបដែលទ្រង់បានធ្វើចំពោះយ៉ូស្វេតាំងពី យូរយារណាស់មកហើយផងដែរ។

## ៦. សំនួរពិភាក្សា

១. តើមេដឹកនាំដំបូងរបស់ជនជាតិអ៊ីស្រាអែលដែលបានស្លាប់ជានរណា? *(ម៉ូសេ)*

២. តើព្រះជ្រើសរើសនរណាដើម្បីធ្វើជាមេដឹកនាំទី ២របស់ជនជាតិអ៊ីស្រាអែល? *(យ៉ូស្វេ)*

៣. តើយ៉ូស្វេគិតថាការធ្វើជាមេដឹកនាំរបស់អ៊ីស្រាអែលគឺជារឿងងាយស្រួលដែរឬទេ? *(ទេ)*

៤. តើអ្នកគួរធ្វើអ្វីនៅពេលមិត្តភក្តិឬសមាជិកគ្រួសាររបស់អ្នកជួបការលំបាកនៅក្នុងជីវិត?
*(លើកទឹកចិត្តពួកគេដូចជារបៀបដែលព្រះបានលើកទឹកចិត្តយើងដែរ)*

## ៧. ខគម្ពីរចងចាំ

***យ៉ូស្វេ ១៖៩*** *“....ចូរឲ្យមានកំឡាំង និងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង ទ្រង់គង់ជាមួយនៅកន្លែងណា ដែលឯងទៅផង”* ។

## ៨. ហត្ថកម្ម «សៀវភៅនៃការលើកទឹកចិត្ត»

១.ថតចម្លងគំរូសៀវភៅដែលអាចបត់បាន(សូមមើលខាង ក្រោម) ហើយខគម្ពីរក៏បោះពុម្ពដែរ។

២.ជួយកុមារឱ្យបត់និងកាត់គំរូសៀវភៅដើម្បីឱ្យពួកគេ អាចបត់វាជាសៀវភៅបាន។ប្រើការណែនាំពីដ្យាក្រាមនៅទីនេះ។



៣.កុមារគួរកាត់ខគម្ពីរលើកទឹកចិត្តហើយបិទភ្ជាប់វាទៅ ក្នុង សៀវភៅតាមលំដាប់ដែលពួកគេចង់បាន។

៤.កុមារអាចតុបតែង និងផាត់ពណ៌សៀវភៅ ហើយប្រើវានៅពេលណាដែលពួកគេត្រូវការការលើកទឹកចិត្តពីព្រះជាម្ចាស់។

**៩. ចំរៀង** (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

**១០. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ផែនការរបស់យើង និងផែនការរបស់ព្រះមិនសុទ្ធតែដូចគ្នានោះទេ។ សព្វថ្ងៃនេះមនុស្សជាច្រើនយល់ថាពួកគេសមនឹងទទួលបានតែរបស់ល្អតែប៉ុណ្ណោះ ព្រោះពួកគេជាមនុស្សល្អ។ ការពិតគឺយើងសមនឹងទទួលបានសេចក្តីស្លាប់ និងការលំបាកយ៉ាងធ្ងន់ធ្ងរចំពោះអំពើបាបរបស់យើង។ ប៉ុន្តែព្រះមិនផ្តល់ឱ្យយើងនូវអ្វីដែលយើងសមនឹងទទួលនោះទេ។ គ្រីស្ទបរិស័ទព្រមប្រើជីវិតរបស់ខ្លួនដើម្បីបំរើព្រះដោយសារតែអ្វីដែល ព្រះជាម្ចាស់បានប្រទានដល់យើង និងអ្វីដែលទ្រង់បានផ្តល់ទៅអ្នកដទៃតាមរយៈយើង។ ការបង្រៀនក្មេងៗ គឺជាព្រះពរ ពីព្រោះព្រះកំពុងប្រើអ្នកដើម្បីផ្សព្វផ្សាយដំណឹងល្អដល់ពួកគេ។ សូមចំណាយពេលខ្លះដើម្បី អរគុណព្រះដែលបានប្រើអ្នកក្នុងការបង្រៀនកុមារ។

ឲ្យឯងគ្រាន់តែមានកំឡាំង នឹងចិត្តក្លាហានប៉ុណ្ណោះ ដើម្បីនឹងកាន់ ហើយប្រព្រឹត្តតាមក្រិត្យវិន័យគ្រប់ជំពូក ដែលម៉ូសេជាអ្នកបំរើអញ បានបង្គាប់មក កុំឲ្យងាកបែរចេញទៅខាងស្តាំ ឬខាងឆ្វេងឡើយ ប្រយោជន៍ឲ្យឯងបានកើតការនៅកន្លែងណាដែលឯងទៅនោះ កុំឲ្យគម្ពីរក្រិត្យវិន័យនេះភ្លេចបាត់ពីមាត់ឯងឡើយ គឺត្រូវឲ្យនឹកជញ្ជឹងទាំងយប់ទាំងថ្ងៃវិញ ដើម្បីឲ្យបានកាន់ ហើយប្រព្រឹត្តតាមអស់ទាំងសេចក្តី ដែលកត់ទុកក្នុងគម្ពីរនេះឯង ដ្បិតគឺយ៉ាងនោះដែលឯងនឹងបានកើតការនៅគ្រប់ទាំងផ្លូវឯង ហើយនឹងបានចំរើនឡើងផង តើអញមិនបានបង្គាប់ឯងទេឬអី ដូច្នេះចូរឲ្យមានកំឡាំងនឹងចិត្តក្លាហានចុះ កុំឲ្យខ្លាចឡើយ ក៏កុំឲ្យស្រយុតចិត្តផង ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯងទ្រង់គង់ជាមួយនៅកន្លែងណា ដែលឯងទៅផង។

(យ៉ូស្វេ ១:៧-៩)

Hot Dog Book (Fold on all lines. Fold in ½ width & cut on dotted line. Fold in length ...

7

6

5

4

8

1

# ព្រះអង្គលើកទឹកចិត្តយើង



ឈ្មោះ:________________

2

3

| | | | |
|---|---|---|---|
| **តើអ្នកសង្ស័យ និងភ័យខ្លាចទេ?**<br>**អេសាយ ៤១:១០**<br>"កុំឲ្យភ័យខ្លាចឡើយ ដ្បិតអញនៅជាមួយនឹងឯង កុំឲ្យស្រយុតចិត្តឲ្យសោះ ពីព្រោះអញជាព្រះនៃឯង អញនឹងចំរើនកំឡាំងដល់ឯង អើ អញនឹងជួយឯង អើ អញនឹងទ្រឯងដោយដៃស្តាំដ៏សុចរិតរបស់អញ។" | **តើអ្នកឯកោឬ? ហេព្រើ ១៣:៥ខ**<br>"អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ។" | **តើអ្នកកើតទុក្ខពីរឿងអ្វីមួយមែនទេ?**<br>**អេសាយ ៥១:១២ក**<br>"អញ គឺអញនេះហើយ ជាអ្នកដែលកំសាន្តចិត្តឯងរាល់គ្នា ។" | **តើអ្នកត្រូវការការពារឬ?**<br>**លោកុប្បត្តិ ២៨:១៥ក**<br>"មើល អញនៅជាមួយនឹងឯង អញនឹងថែរក្សាឯងនៅកន្លែងណាដែលឯងទៅ ។" |
| **តើអ្នកមិនសប្បាយចិត្តមែនទេ?**<br>**នេហេមា ៨:១០គ**<br>កំកុំឲ្យមានចិត្តព្រួយឡើយ ពីព្រោះសេចក្តីអំណររបស់ព្រះយេហូវ៉ាជាកំឡាំងនៃអ្នករាល់គ្នា។" | | **តើជំងឺជាបញ្ហាមែនទេ?**<br>**និក្ខមនំ ១៥:២៦ខ**<br>"ដ្បិតអញនេះជាយេហូវ៉ា គឺជាព្រះដែលប្រោសឯងរាល់គ្នាឲ្យជា។" | **តើអ្នកត្រូវការសន្តិភាពឬ?**<br>**ភីលីព ៤:៧**<br>"យ៉ាងនោះសេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត និងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នា ក្នុងព្រះគ្រីស្ទយេស៊ូវ។" |